# អំពីឈ្មោះប្រាសាទភ្នំជីសូរ្យ

ភ្នំជីសូរ្យ ស្ថិតនៅក្នុងភូមិស្វា ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។ ទីនេះមានភាពល្បីល្បាញ ដ្បិតជាទីទេសចរនិយមមកលម្ហែផង មានវត្ត និងជាទីបុរាណដ្ឋានដែលមានប្រាសាទបុរាណយ៉ាងសម្បើមផងដែរ។ ឈ្មោះភ្នំនេះ អ្នកស្រុកតែងពន្យល់តាមរឿងព្រេង ដូចមាននៅក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរ ភាគ៦ របស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ[១]។ យ៉ាងនេះក្ដី តាមការសិក្សាសិលាចារឹក បានបង្ហាញពីឈ្មោះ "**ជីសូរ្យ**" នេះ ជាឈ្មោះបន្សល់មកតាំងពីបុរាណយ៉ាងជាក់ច្បាស់។

ប្រាសាទបុរាណនៅលើភ្នំនេះ មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ខាងក្នុងមានតួប្រាសាទជាច្រើន និងមានប្រាង្គសំខាន់នៅចំកណ្ដាល ដែលអ្នកស្រុកហៅថា "**វិហារក្នុង**" ជាទីដែលគេជឿថាមានភាពសក្ដិសិទ្ធិ។ "**វិហារក្នុង**" ជាការកែប្រែប្រាង្គព្រហ្មញ្ញសាសនាមកជាចេតិយតាមបែបពុទ្ធសាសនា ជាការពេញនិយមនាសម័យកណ្ដាល។ ប្រាសាទនេះកសាងនៅក្នុងរាជ្យរបស់**ព្រះបាទសូរ្យវរ្ម័ទី១**(១០០២-១០៥០គ.ស.) ដែលទំនងជាសាងសង់នៅលើទីតាំងប្រាសាទសម័យមុនអង្គរ ព្រោះយើងសង្កេតឃើញមានសម្ភារៈសំណង់សម័យមុនអង្គរនៅទីនោះផងដែរ។ បើឈរលើភ្នំចំខាងមុខប្រាសាទនេះ យើងឃើញមានជណ្ដើរបុរាណសាងពីថ្មបាយក្រៀមចុះទៅដល់ជើងភ្នំ។ នៅជើងភ្នំទិសខាងកើតមានប្រាសាទពីរ ដែលជាច្រកចូលមកកាន់ប្រាសាទលើភ្នំ ហៅតាមពាក្យសំស្ក្រឹតថា "**គោបុរៈ**"។ អ្នកស្រុកហៅប្រាសាទទាំងពីរនោះថា ប្រាសាទសែនត្នុល និងសែនរាំង ឬសែនភូរាំង។ នៅខាងកើតប្រាសាទទាំងពីរនោះមានស្រះទឹកបុរាណមួយ អ្នកស្រុកហៅថា "**ទន្លេអុំ**" ដែលជាបារាយណ៍របស់ប្រាសាទនេះ គឺជានិមិត្តរូបតំណាងឱ្យមហាសាគរ។

នៅប្រាសាទនេះ គេបានរកឃើញសិលាចារឹកចំនួន៤ផ្ទាំង ដែលមានចុះលេខបញ្ជី K. 31 K.32 K.33 និង K.34។ សិលាចារឹក K.31 ចុះកាលបរិច្ឆេទនៅឆ្នាំ១០២៩គ.ស.ចារនៅលើមេទ្វារខាងជើងនៃតួប្រាសាទខាងជើង ចារឹកអំពីជង្វាយរបស់ព្រះសូរ្យវរ្ម័ទី១ មានមនុស្សពីរនាក់មានឋានន្តរនាមជា "**ឆ្មោញ**" និង "**តេង**" ព្រមទាំងដី១២កន្ធែង និងអម្រស់អម្រ

---

[១] សូមអានបន្ថែម៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ទំព័រ៥៣-៦៣។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

របស់អ្នកបម្រើ ចំពោះប្រាសាទនេះ[២]។ សិលាចារឹក K.32 បច្ចុប្បន្នរក្សាទុកនៅសារមន្ទីរជាតិអង្គរមានចុះកាលបរិច្ឆេទនៅឆ្នាំ១១១៦គ.ស ចារឹកអំពីដង្វាយរបស់ព្រះគម្តែងអញភ្នំវហែក ជាតបស្វីរបស់រាជការ ថ្វាយជាដី ខ្ញុំបម្រើ និងកស្តុភារសម្រាប់ធ្វើពិធីសង្រ្កាន្តចំពោះប្រាសាទនេះ។ ចុងក្រោយមានពាក្យបណ្តាសាដល់នរណាដែលបំផ្លាញបុណ្យទាំងនោះឱ្យធេះសន្ធោរសន្ធៅដូចភ្លើងនៅនរកពោរព[៣]។ សិលាចារឹក K.33 រក្សាទុកនៅសារមន្ទីរហ្គីមេត៍ប្រទេសបារាំង ចុះកាលបរិច្ឆេទនៅឆ្នាំ១០១៧គ.ស ផ្នែកដំបូងចាររំលឹកពីការដាវដីសាងអាស្រមឈ្មោះយោគិន្ទ្រាល័យ និងបន្ទាប់មកនៅឆ្នាំ១០១៧គ.ស មានស្តែងអញសិវាចារ្យទូលសុំឱ្យព្រះបាទសូរ្យវម៌្មទី១ ចេញលិខិតព្រះអាលក្ស ដល់លោកដែលលោកបានដាវដីយោគិន្ទ្រាល័យ និងយោគិន្ទ្របុរកន្ទង់មក ដោយរៀបរាប់នូវទ្រព្យដែលបានទិញដីនោះ និងដង្វាយនានាថ្វាយព្រះ។ ចុងក្រោយ គឺជាបណ្តាសាដល់អ្នកដែលបំផ្លាញ និងពរដល់អ្នកថែរក្សាទ្រព្យទាំងនោះ[៤]។ សិលាចារឹក K.34 បច្ចុប្បន្នរក្សាទុកនៅសារមន្ទីរហ្គីមេត៍ប្រទេសបារាំង ចារឹកនៅស.វ.ទី១១ និយាយអំពីការធ្វើបុណ្យរបស់ទិវាករបណ្ឌិត និងដង្វាយក្រុមមនុស្ស៦៨នាក់ដែលមានឋានន្តរនាមជា "**លោញ**" និង "**តេង**" ដើម្បីបម្រើនៅតំបន់រលាបទន្ធា ដោយមានបញ្ជាក់ពីព្រំដីរលាបទន្ធា និងដីពីកន្លែងទៀតផង។ បន្ទាប់មកមានរៀបរាប់អំពីដង្វាយនានា។ ខាងចុងបញ្ចប់អត្ថបទ ជាពរជូនដល់អ្នកបានថែរក្សាបុណ្យ និងបណ្តាសារដល់នរណាដែលបំផ្លាញបុណ្យដែលបានសាងនេះ[៥]។

សិលាចារឹកប្រាសាទភ្នំជីសូរ្យ K.31 K.32 និង K.34 បានបញ្ជាក់ថាប្រាសាទនេះមានឈ្មោះដើមថា "**វ្រះកម្រតេងឝ៑ជគត៑ឝ្រីសូយ៌្យបវ៌្វត**" សម្រួលជាអក្ខរាវិរុទ្ធទំនើបថា "**ព្រះគម្តែងជគតស្រីសូរ្យបព៌ត**"។ ឯសិលាចារឹកប្រាសាទព្រះវិហារ K.380 ហៅប្រាសាទនេះថា "**ឝ្រីសូយ៌្យាទ្រិ**" (**ឝ្រីសូយ៌្យ + អទ្រិ**) សម្រួលមកជាអក្ខរាវិរុទ្ធទំនើបថា "**សូរ្យាទ្រិ**"។ ចំណែកសិលាចារឹក

[២] សូមអានបន្ថែម៖ Cœdès 1942: 29-30

[៣] សូមអានបន្ថែម៖ Cœdès 1942: 137-139

[៤] សូមអានបន្ថែម៖ Cœdès 1951: 148-152

[៥] សូមអានបន្ថែម៖ Cœdès 1951: 152-156

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

*ប្រាសាទបាយ័ន K.293 វិញ ហៅប្រាសាទនេះថា "**វ្រះកម្រតេងជគតិត្រីសូយ៌្យ គិរី**" សម្រួលមកអក្ខរាវិរុទ្ធទំនើបជា "**ព្រះគម្តែងជគតស្រីសូរ្យគិរី**"។*

*យើងសង្កេតឃើញថា ឈ្មោះប្រាសាទនេះមានធាតុសំខាន់ពីរគឺ «**ត្រីសូយ៌្យ**» (**ស្រីសូរ្យ**) **ផ្សំនឹង** «**បវ៌្វត**» «**អទ្រិ**» «**គិរី**»។ ពាក្យ «**ស្រីសូរ្យ**» នេះគឺសំដៅព្រះបាទសូរ្យវម៌្មទី១ ដែលទ្រង់ជាស្ថាបនិកប្រាសាទនេះ។ ចំណែកឯពាក្យសំស្ក្រឹត «**បវ៌្វត**» «**អទ្រិ**» **និង** «**គិរី**» មានន័យថាភ្នំដូចគ្នា។ ដូច្នេះឈ្មោះបុរាណរបស់ភ្នំជីសូរ្យដែលរៀបរាប់ក្នុងសិលាចារឹកខាងលើមកនេះ មានន័យថា «**ភ្នំព្រះស្រីសូរ្យ**» ឬ «**ភ្នំព្រះបាទសូរ្យវម្ម៌(ទី១)**»។*

*«**ភ្នំជីសូរ្យ**» ជាឈ្មោះបង្ហាញពីការចងចាំឈ្មោះបុរាណរបស់ប្រាសាទនេះថា «**ស្រីសូរ្យបព៌ត**» «**ស្រីសូរ្យាទ្រិ**» ឬ «**ស្រីសូរ្យគិរី**»។ ពាក្យ «**ជី**» អាចឱ្យយើងពិចារណាបានច្រើនយ៉ាង។ ករណីទី១ ពាក្យ «**ជី**» ជាពាក្យសម្គាល់ញាតិកាខាងលើចាប់ពីពីរថ្នាក់ឡើងទៅ។ ដូច្នេះ «**ភ្នំជីសូរ្យ**» មានន័យយ៉ាងសាមញ្ញថាភ្នំរបស់តាសូរ្យ។ ករណីទី២ ពាក្យ «**ជី**» អាចជាពាក្យមានការវិវត្តសូរមកពីពាក្យ «**ស្រី**» ដែលជាពាក្យសំស្ក្រឹត(អានថា ស្រ៊ី)។ អ្វីដែលយើងគួរចាប់អារម្មណ៍ ជាទូទៅយើងសម្គាល់ឃើញថាសម្តីអ្នកស្រុកតាកែវ-កំពត សូរព្យញ្ជនៈ "**ស**" បញ្ចេញជាសូរព្យញ្ជនៈ "**ច/ជ**" វិញ។ ដូច្នេះពាក្យ «**ស្រី**» នេះអាចក្លាយមកជាសូរ «**ច្រី**» ឬ «**ជ្រី**» ដែលមានការធ្លាក់ចុះសូរ "**រ**" ក្លាយជាសូរ «**ជី**»។*

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង*




ប្រាសាទភ្នំជីសូរ្យមើលពីចម្ងាយនិងពីប្រាសាទសែនត្នុល




ប្រាសាទសែនត្នុលនិងប្រាសាទសែនរាំង




ជណ្តើរបុរាណនិងផ្លូវបុរាណពីប្រាសាទសែនត្នុលទៅទន្លេអុំ




ប្រាសាទភ្នំជីសូរ្យមើលពីខាងមុខនិងជ្រុងភ្លៀសាន

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹកប្រាសាទភ្នំជីសូរ្យ K.32



សិលាចារឹកប្រាសាទបាយ័ន K.293-3

## ឯកសារយោង


វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

២០០២. ប្រជុំរឿងព្រេងខ្មែរ ភាគ៦, ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

**Cœdès, G.**

1942. *Inscriptions du Cambodge (vol. 2)*. Paris, P Geuthner.
1951. *Inscriptions du Cambodge (vol. 3)*. Paris, P Geuthner.


អត្ថបទដោយ៖ ហ៊ុន ឈុនតេង